00754748

សាធារណៈ / Public

E131/10

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 23 / 11 / 2011
ម៉ោង (Time/Heure): 10:40
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

## អង្គជំនុំជម្រះសាលាដំបូង

កាលបរិច្ឆេទ: ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១១

**ជូនចំពោះ:** សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង ០០២

**ពី:** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន:** លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ:** សេចក្តីជូនដំណឹងជាមុនអំពីការចាត់តាំងភារកិច្ចសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៣ រូបក្នុងអំឡុងសវនាការជំនុំជម្រះដំណាក់កាលដំបូង (ពីថ្ងៃទី ០៥ ដល់ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១១)

ដូចដែលបានបញ្ជាក់នៅក្នុងអនុស្សរណៈមួយចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ របស់មន្ត្រីច្បាប់ជាន់ខ្ពស់ផ្ញើទៅកាន់ភាគី (ឯកសារ E141) នោះ លោកប្រធានអង្គជំនុំជម្រះ តាមរយៈអនុស្សរណៈនេះ អាចចាត់តាំងសហព្រះរាជអាជ្ញា ក្រុមមេធាវីការពារក្តីនីមួយៗ ឬសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីឱ្យទទួលខុសត្រូវសំខាន់ក្នុងការសួរដេញដោលសាក្សី អ្នកជំនាញ ឬដើមបណ្តឹងរដ្ឋប្បវេណីណាម្នាក់នៅសវនាការ។ បន្ទាប់ពីប្រធានអង្គជំនុំជម្រះសួរសំណួរទៅកាន់សាក្សី អ្នកជំនាញ ឬដើមបណ្តឹងរដ្ឋប្បវេណី និងពិនិត្យលើបញ្ហាបឋមរួចហើយ សហមេធាវីនាំមុខ ឬភាគី អាចសួរសំណួរពួកគេទៅតាមការពាក់ព័ន្ធ។

តាមរយៈអនុស្សរណៈនេះ អង្គជំនុំជម្រះសាលាដំបូងសូមចាត់តាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីឱ្យទទួលខុសត្រូវក្នុងការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីចំនួន៣រូប ដែលមានបង្ហាញអត្តសញ្ញាណនៅក្នុងឧបសម្ព័ន្ធ ខ សម្ងាត់ (ឯកសារ E131/1.2) ដែលអាចត្រូវបានស្តាប់ចម្លើយក្នុងអំឡុងសវនាការដំណាក់កាលដំបូងនេះ។ អង្គជំនុំជម្រះសូមរំឭកសហមេធាវីនាំមុខថា ការសួរដេញដោលរបស់ខ្លួនត្រូវកំហិតត្រឹមអង្គហេតុនានាពាក់ព័ន្ធនឹងសវនាការដំណាក់កាលដំបូងនេះ និងទុក្ខវេទនារបស់ដើមបណ្តឹងរដ្ឋប្បវេណីដោយសារអង្គហេតុទាំងនេះប៉ុណ្ណោះ។ សាក្សីដែលនឹងត្រូវស្តាប់ចម្លើយក្នុងអំឡុងសវនាការដំណាក់

កាលដំបូងនេះ នឹងកំហិតត្រឹមចំណុចអង្គហេតុនានាពាក់ព័ន្ធនឹងសវនាការលើចំណុចអង្គហេតុទាំងនោះតែប៉ុណ្ណោះ។

ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីយល់ឃើញថាខ្លួនគួរគប្បីបញ្ចេញទស្សនៈលើបញ្ហាផ្សេងៗដែរនោះ ខ្លួនអាចស្នើសុំដោយផ្ទាល់មាត់មកកាន់អង្គជំនុំជម្រះសាលាដំបូង ដើម្បីសម្រេចថាតើការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋ-ប្បវេណីលើចំណុចអង្គហេតុផ្សេងមានប្រយោជន៍ធ្វើឱ្យការរៀបចំសវនាការទទួលបានប្រសិទ្ធភាពដែរ ឬទេ។ ថ្វីបើដូច្នេះ អង្គជំនុំជម្រះសូមបញ្ជាក់ថាការស្នើសុំទាំងនេះពុំងាយទទួលបានការឯកភាពឡើយ។

សហមេធាវីនាំមុខគួរគប្បីត្រៀមរៀបចំធ្វើការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៣ រូបនេះ នៅថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១ ដោយហេតុថានាពេលបច្ចុប្បន្នអង្គជំនុំជម្រះពុំដឹងប្រាកដថាតើជនជាប់ចោទណាម្នាក់នឹងឆ្លើយសំណួរឡើយ។ ក្នុងករណីជនជាប់ចោទមិនឆ្លើយសំណួរ អង្គជំនុំជម្រះនឹងងាកទៅស្តាប់សក្ខីកម្មសាក្សីនិងដើមបណ្តឹងរដ្ឋប្បវេណីដែលបានបង្ហាញអត្តសញ្ញាណនៅក្នុងឯកសារ E131/1.2។